00749625

E101/5

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 10 / 2011
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សាធារណៈ / Public

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អនុស្សរណៈ - អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ៖ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿងលេខ ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ (ឯកសារ E101 និង E101/1)**

សហព្រះរាជអាជ្ញាបានស្នើសុំមកអង្គជំនុំជម្រះ ឲ្យបង្គាប់ទៅជនជាប់ចោទ ដើម្បីធ្វើការបញ្ជាក់អំពីចេតនារបស់គាត់ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មនៅពេលសវនាការ (ឯកសារ E101 និង E101/1)។ សហព្រះរាជ-អាជ្ញាបានលើកឡើងថា ទោះបីជាជនជាប់ចោទមានសិទ្ធិជាសារវ័ន្តក្នុងការនៅស្ងៀមមិនឆ្លើយតបក្តី ប៉ុន្តែប្រសិនបើជនជាប់ចោទសម្រេចថា គាត់នឹងផ្តល់សក្ខីកម្មក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនោះ សហព្រះរាជអាជ្ញាត្រូវការ ការជូនដំណឹងជាមុនអំពីបញ្ហានេះ ដើម្បីផលប្រយោជន៍នៃការត្រៀមរៀបចំសវនាការប្រកបដោយប្រសិទ្ធភាព។

នៅក្នុងឯកសារ E131/1.2 (ឧបសម្ព័ន្ធ ខ) ដែលជាប្រភេទឯកសារសម្ងាត់ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ដោយអនុលោមតាមវិធាន ៨៩ *ស្ទួន* (២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងចាប់ផ្តើមសវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ដោយការតាំងសំណួរទៅជនជាប់ចោទ។ ហេតុដូច្នេះ សូមសហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា ជនជាប់ចោទអាចធ្វើការឆ្លើយតបទៅនឹងសំណួរណាមួយ នៅក្នុងសវនាការលើអង្គសេចក្តី នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឬនៅក្នុងអំឡុងពេលថ្ងៃបន្តបន្ទាប់ បន្ទាប់ពីបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់រួច។ អង្គជំនុំជម្រះបានឃើញសេចក្តីបញ្ជាក់របស់មេធាវីការពារក្តីឱ្យជនជាប់ចោទ អៀង សារី កាលពីថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ដែលថា ជនជាប់ចោទ អៀង សារី ពុំមានបំណងផ្តល់សក្ខីកម្ម ឬឆ្លើយទៅនឹងសំណួរក្នុងអំឡុងពេលសវនាការឡើយ (ឯកសារ E101/4)។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ជនជាប់ចោទអាចធ្វើការឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះបាន ប្រសិនបើគាត់មានបំណងឆ្លើយតប ឬអាចធ្វើសេចក្តីសន្និដ្ឋានណាមួយ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង (*ឧទាហរណ៍* វិធាន ៩៤(១)(ឃ) នៃវិធានផ្ទៃក្នុង)។ ក្នុងន័យដើម្បីឱ្យការរៀបចំសវនាការធ្វើឡើងប្រកបដោយប្រសិទ្ធភាព អង្គជំនុំជម្រះនឹងផ្តល់ការណែនាំបន្ថែមទៀត ពាក់ព័ន្ធនឹងដំណើរការសវនាការលើសំណុំរឿងលេខ ០០២ ។

នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើ E101 និងE101/1។